**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៧៤/២៥ **ក.ប**/ប្រ.ក.ជ.ក

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការដោះស្រាយវិវាទការងាររួម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២០/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញព្រះរាជក្រមលេខ នស០១១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ ដែល/១០២១/រកម/ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧/០៣៩៧/រកម/
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

### ប្រការ១ .-

ចំពោះវិវាទការងាររួម ភាគីណាមួយអាចប្តឹងទៅនាយកដ្ឋានវិវាទការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន លើកលែងតែមានអនុសញ្ញារួម ដែលបានចែងពីនីតិវិធីច្បាស់លាស់សម្រាប់ដោះស្រាយវិវាទការងាររួមនោះ។

### ប្រការ២ .-

ក្រោយពីបានទទួលបណ្តឹង អធិការការងារនឹងពិនិត្យមើលសំណុំរឿង ដើម្បីចាត់វិធានការបន្តជាអាទិ៍៖

- ផ្សះផ្សា ឬ
- ចុះធ្វើអធិការកិច្ចការងារ។

### ប្រការ៣ .-

ក្រោយពីបានពិនិត្យសំណុំរឿងរួច អធិការការងារត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់តាំងអ្នកផ្សះផ្សាម្នាក់ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង។

ការផ្សះផ្សា ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីពេលទទួលបានការចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

### ប្រការ៤ .-

អ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញទៅភាគីវិវាទមកផ្តល់នូវព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីជាមូលដ្ឋានក្នុងការផ្សះផ្សាវិវាទការងាររួមនេះ។

ការសាកសួរព័ត៌មានពីភាគីវិវាទ ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា។ គ្រប់ពេលសាកសួរព័ត៌មានត្រូវធ្វើកំណត់ហេតុដោយមានចុះហត្ថលេខារបស់អ្នកផ្សះផ្សា និងចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃរបស់ភាគីវិវាទដែលផ្តល់ព័ត៌មាននោះ ហើយកំណត់ហេតុនេះត្រូវផ្តល់ជូនភាគីវិវាទដែលផ្តល់ព័ត៌មានចំនួន ១ (មួយ) ច្បាប់។

ក្នុងករណីដែលទទួលព័ត៌មានសព្វគ្រប់ពីភាគីទាំងអស់ហើយ អ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញម្តងទៀតឱ្យភាគីវិវាទទាំងអស់មកចូលរួមប្រជុំជាមួយគ្នាដើម្បីផ្សះផ្សា។

នៅពេលកំពុងផ្សះផ្សា ភាគីវិវាទត្រូវបញ្ឈប់គ្រប់វិធានការវិវាទ។

**ប្រការ៥ ._**

ភាគីត្រូវចូលរួមនៅគ្រប់ពេលប្រជុំ ដែលអ្នកផ្សះផ្សាបានកោះអញ្ជើញ។ ករណីអវត្តមានដែលគ្មានបញ្ជាក់មូលហេតុត្រឹមត្រូវ ត្រូវទទួលពិន័យ ដូចមានចែងក្នុងមាត្រា៣៦៣ នៃច្បាប់ស្តីពីការងារ។

**ប្រការ៦ ._**

ករណីដែលដើមចោទមិនសហការ ឬមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើឯកសារ ដែលតម្រូវដោយអ្នកផ្សះផ្សានៅក្នុងកិច្ចដំណើរការនៃនីតិវិធីរបស់ខ្លួនស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ពាក្យបណ្តឹងនោះត្រូវទុកជាមោឃៈ។

ពាក្យបណ្តឹងដែលត្រូវបានចាត់ទុកជាមោឃៈ ដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ មិនអាចត្រូវបានទទួលយកមកចាត់ការក្នុងនីតិវិធីនៃការផ្សះផ្សានោះទេ ក្នុងករណីមានការដាក់ពាក្យបណ្តឹងសាជាថ្មី។

**ប្រការ៧ ._**

លិខិតអញ្ជើញដែលមានចែងក្នុងប្រការ៤ខាងលើ ត្រូវផ្ញើជូនភាគីវិវាទតាមលិខិតអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃថាបានទទួល ឬតាមមធ្យោបាយផ្សេងទៀត ដែលចាត់ទុកថាបានការ។

**ប្រការ៨ ._**

ការផ្សះផ្សាវិវាទការងាររួម ត្រូវមានការចូលរួមពីសហជីពដែលមានភាពជាតំណាងបំផុត ឬសហជីពដែលមានសមាជិកភាគតិចក្នុងករណីដែលវិវាទការងាររួមមិនកើតចេញពីការអនុវត្តអនុសញ្ញារួម។

ក្នុងករណីសហគ្រាស ឬគ្រឹះស្ថានដែលពុំទាន់មានសហជីព ការផ្សះផ្សាវិវាទការងាររួមត្រូវមានការចូលរួមពីអ្នកតំណាងកម្មករនិយោជិត ដែលអ្នកផ្សះផ្សាបានចេញលិខិតបញ្ជាក់។

**ប្រការ៩ ._**

អ្នកផ្សះផ្សាត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់ព្រមសះជានឹងគ្នា។ កំណត់ហេតុនៃការផ្សះផ្សាត្រូវចុះទិដ្ឋាការដោយអ្នកផ្សះផ្សាព្រមទាំងហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីដែលពាក់ព័ន្ធ និងត្រូវចម្លងជូនភាគីវិវាទផង។

**ប្រការ១០ ._**

ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីវិវាទ និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សា មានតម្លៃនិងអានុភាពដូចគ្នានឹងអនុសញ្ញារួមរវាងភាគីវិវាទ និងរវាងអ្នកដែលឱ្យគេតំណាងខ្លួន។ ប៉ុន្តែប្រសិនបើភាគីតំណាងកម្មករនិយោជិត ពុំមែនជាសហជីពណាមួយទេ ការព្រមព្រៀងនេះមិនជំទាស់ទាំងចំពោះសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលឱ្យគេតំណាងខ្លួន។

**ប្រការ១១ ._**

ចំពោះវិវាទការងាររួមដែលភាគីពុំបានប្តឹង ឬឱ្យដំណឹងមកអធិការការងារទេនោះ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចាត់ការធ្វើការផ្សះផ្សាតាមនីតិវិធីដែលកំណត់ក្នុងប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ ប្រការ៩ និងប្រការ១០ ខាងលើ ក្រោយពីបានដំណឹងពីវិវាទនេះភ្លាម។

**ប្រការ១២ .-**

វិវាទការងាររួមណាដែលមានការប៉ះពាល់ ឬអាចបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ អធិការការងារ ក្រោយពីទទួលបានដំណឹងស្តីពីវិវាទនេះ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់តាំងអ្នកផ្សះផ្សា និងចាត់ការធ្វើការផ្សះផ្សាភ្លាមៗ ចុះសាកសួរព័ត៌មាន និងធ្វើការផ្សះផ្សាដល់ទីកន្លែងតែម្តង។

**ប្រការ១៣ .-**

ក្នុងរយៈពេល២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការផ្សះផ្សាវិវាទការងាររួមមិនសះជា ភាគីវិវាទអាចស្នើសុំជាលាយលក្ខណ៍អក្សររួមគ្នាមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សះផ្សាសាឡើងវិញ។

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចចាត់តាំង ឬប្តូរអ្នកផ្សះផ្សាដើម្បីផ្សះផ្សាវិវាទការងារនេះសាឡើងវិញបានស្របតាមនីតិវិធី ដែលមានចែងក្នុងប្រកាសនេះ។

ប្រសិនបើការផ្សះផ្សាវិវាទការងារសាឡើងវិញនេះមិនទទួលបានលទ្ធផលសះជា ភាគីវិវាទមិនអាចស្នើសុំឱ្យផ្សះផ្សាសាឡើងវិញម្តងទៀតបានទេ ដោយត្រូវអនុវត្តតាមនីតិវិធីបន្តសម្រាប់ការដោះស្រាយវិវាទការងារ។

**ប្រការ១៤ .-**

ចំពោះវិវាទការងាររួមដែលផ្សះផ្សាមិនសះជា អ្នកផ្សះផ្សាត្រូវរាយការណ៍ក្នុងរយៈពេល៤៨ (សែសិបប្រាំបី) ម៉ោង ជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីមានចំណាត់ការបន្តទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេល៣ (បី) ថ្ងៃ។

**ប្រការ១៥ .-**

ប្រកាសលេខ៣១៧ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ